00698515

E85/2

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន: សម្ងាត់ / Confidential / Confidentiel

ឈ្មោះមន្ត្រីកត់ត្រា: សាធារណៈ / Public

ហត្ថលេខា: 04/11/2011

---

**សេចក្ដីបន្ថែមចំពោះញត្តិរបស់ អៀង សារី សុំកោះហៅសម្ដេចព្រះមហាធីរៈក្សត្រនរោត្តម សីហនុ នាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និងសម្ដេច ជា ស៊ីម**

---

**ដាក់ដោយ៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្ដម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្ដារ៉ា

ចៅក្រមបំរុង Claudia FENZ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 19 / 05 / 2011

ម៉ោង (Time/Heure): 16:02

មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមដាក់សេចក្តីបន្ថែមចំពោះញត្តិរបស់គាត់ ដើម្បីកោះហៅសម្តេចព្រះមហាវីរៈក្សត្រនរោត្តម សីហនុ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធ និងសម្តេច ជា ស៊ីម[1]។ សេចក្តីបន្ថែមនេះផ្តល់ការគាំទ្របន្ថែមទៀតដែលថាអត្ថបទនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស មិនច្បាស់លាស់[2] ។ អត្ថបទនេះមិនអាចរកបានទេនៅពេលមេធាវីការពារក្តីដាក់ញត្តិនេះ ។

១. នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយដែលមានចំណងជើងថា “ការដាក់អញ្ញត្រកម្មបន្ថែម (ការលើកលែងទោស និងការអនុគ្រោះទោស)”[3]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់នៅក្នុងអនុស្សរណៈនេះថា “នៅក្នុងសារណាររបស់ខ្លួនភាគីបាននិយាយយោងចំពោះអត្ថិភាពនៃអត្ថបទបកប្រែនៃព្រះរាជក្រឹត្យនេះនៅក្នុងសំណុំរឿងដែលមានជាភាសាអង់គ្លេស និងភាសាខ្មែរតែប៉ុណ្ណោះ ។ អង្គបុរេជំនុំជម្រះកាលពីលើកមុនបានយោងទៅលើអត្ថបទបកប្រែដែលមិនផ្លូវការ និងខុសគ្នារបស់ព្រះរាជក្រឹត្យនេះ ។ ភ្ជាប់ជាមួយសេចក្តីបន្ថែមនេះ គឺជាអត្ថបទបកប្រែរបស់ព្រះរាជក្រឹត្យដែលស្នើឡើងដោយអង្គជំនុំជម្រះសាលាដំបូង និងត្រូវបានបកប្រែដោយអង្គភាពបកប្រែឯកសារ និងសំណេរ (“ITU”) ពីអត្ថបទដើមជាភាសាខ្មែរ ទៅជាភាសាបារាំង និងភាសាអង់គ្លេស”[4] ។ មកដល់ថ្ងៃនេះ វាគឺជាអត្ថបទបកប្រែលើកទី៣ហើយនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ដែលត្រូវបានប្រើប្រាស់នៅ អវតក[5] ។

---

[1] ញត្តិរបស់ អៀង សារី ស្នើសុំកោះហៅសម្តេចព្រះមហាវីរៈក្សត្រនរោត្តម សីហនុ នាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រះអង្គម្ចាស់នរោត្តមរណឫទ្ធិ និងសម្តេច ជា ស៊ីម ចុះថ្ងៃទី ៩ ខែឧសភា ឆ្នាំ២០១១ E85 ។

[2] ដូចខាងលើ នៅកថាខណ្ឌទី ១៦-២៥ ។

[3] អនុស្សរណៈពីអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនក្រុមការពារក្តី អៀង សារី ដែលមានចំណងជើងថា “ការដាក់អញ្ញត្រកម្មបន្ថែម” (ការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១១ E51/8។

[4] ដូចខាងលើ ។

[5] មេធាវីការពារក្តីបានប្រើអត្ថបទបកប្រែដែលជាអត្ថបទបកប្រែលើកដំបូង និងត្រូវបានដាក់នៅក្នុងសំណុំរឿង (ឯកសារ D366/7.1.191 ដែលដាក់នៅក្នុងសំណុំរឿងនៅថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០១០) ហើយវាក៏ជាអត្ថបទបកប្រែមាននៅក្នុងកម្រងឯកសារច្បាប់របស់ អវតក ដែលតម្កល់នៅក្នុង “Drive G” ដែលអាចរកបានដោយភាគី និងអង្គជំនុំជម្រះទាំងអស់នៅ អវតក ។ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា “អត្ថបទភាសាខ្មែររបស់ព្រះរាជក្រឹត្យនេះ ត្រូវបានបកប្រែជាភាសាអង់គ្លេសដោយអ្នកបកប្រែរបស់តុលាការនេះ ។ ហេតុដូច្នេះ អត្ថបទបកប្រែនេះខុសគ្នាពីអត្ថបទភាសាអង់គ្លេសនៃឯកសារនៅក្នុងសំណុំរឿង ។ សាល

E85/2

២. ការប្រើប្រាស់អត្ថបទបកប្រែលើកទី៣នៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស នៅអវតក គឺជាការចង្អុលបង្ហាញបន្ថែមទៀតថាអត្ថបទរបស់ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសមិនច្បាស់លាស់ ។ មានតែតាមរយៈភស្តុតាងអំពីអ្នកដែលពាក់ព័ន្ធនៅក្នុងការចរចារ ការពង្រាង ការអនុញ្ញាត និងការអនុម័តព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសទេ ទើបវិសាលភាពរបស់ព្រះរាជក្រឹត្យនៃការលើកលែងទោស និងអនុគ្រោះទោស អាចកំណត់បាន ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

**ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

---

ដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/73 ក្នុងអក្សរក្នុងលេខយោងលេខ ១៦ "អត្ថបទបកប្រែជាភាសាអង់គ្លេសចេញពីភាសាដើមភាសាខ្មែរដោយអង្គបុរេជំនុំជម្រះ ដោយមានជំនួយពីអ្នកបកប្រែដែលចាត់តាំងដោយអង្គជំនុំជម្រះ" ។ អត្ថបទបកប្រែនេះ ដែលត្រូវបានបកប្រែដោយអង្គបុរេជំនុំជម្រះនៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន គឺខុសគ្នាពីអត្ថបទបកប្រែជាភាសាអង់គ្លេសនៃឯកសារនៅក្នុងសំណុំរឿង ហើយដែលក្រុមមេធាវីការពារក្តី អៀង សារី បានយកមកប្រើប្រាស់នៅក្នុងបណ្តឹងឧទ្ធរណ៍ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១ D427/1/30។